**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Nov-2013, 14:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**មតិរបស់សហព្រះរាជអាជ្ញា លើរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ សម្រាប់សំណុំរឿង ០០២/០២**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម យូ ឧត្តរា
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង ធូ មុន្នី
ចៅក្រមបម្រុង Claudia FENZ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

## សេចក្តីសន្និដ្ឋាន

១. ឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣[1] ដែលជម្រាបជូនភាគីអំពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី១១ ថ្ងៃទី១២ និងប្រសិនបើចាំបាច់ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីពិភាក្សាអំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងសំណុំរឿង00២/0២នោះ សហព្រះរាជអាជ្ញាសូមផ្តល់ជូនជាមតិយោបល់ដូចតទៅ។

២. សហព្រះរាជអាជ្ញាស្នើថា របៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ ដាក់បញ្ចូលនូវកិច្ចពិភាក្សាស្តីពីរបៀបដែលភ័ស្តុតាងត្រូវបានបង្ហាញនៅក្នុងអំឡុងពេលនៃសំណុំរឿង 00២/0១ នឹងត្រូវបានដាក់បញ្ចូលយ៉ាងដូចម្តេចក្នុងសំណុំរឿង 00២/0២។ សហព្រះរាជអាជ្ញា សូមជូនដំណឹងជាមុនថា តាមគោលជំហររបស់ខ្លួន គឺចង់ឲ្យភ័ស្តុតាងដែលបានបង្ហាញក្នុងសំណុំរឿង 00២/0១ ត្រូវបានពិចារណា ជាភ័ស្តុតាងដែលមានក្នុងកំណត់ហេតុរួចជាស្រេចសម្រាប់គោលបំណងនៃសំណុំរឿង 00២/0២ ដោយពុំចាំបាច់ឲ្យមានការដាក់សំណើសុំបន្ថែមណាមួយពីគូភាគី ឬទម្រង់ណាមួយនៃការទទួលស្គាល់តាមផ្លូវតុលាការពីអង្គជំនុំជម្រះសាលាដំបូងឡើយ នៅក្នុងសំណុំរឿង 00២/0២។

៣. ប្រហាក់ប្រហែលគ្នានេះ សហព្រះរាជអាជ្ញាសូមស្នើថារបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការដាក់បញ្ចូលផងដែរ នូវការពិភាក្សាពីផលប៉ះពាល់អ្វីខ្លះដែលការរកឃើញអង្គហេតុនានាក្នុងសាលក្រមសវនាការ ក្នុងសំណុំរឿង 00២/0១ ចំពោះសំណុំរឿង 00២/0២។ តាមគោលជំហររបស់សហព្រះរាជអាជ្ញាគឺថា គេពុំចាំបាច់ធ្វើសច្ចទស្សន៍តុលាការណាមួយអំពីការរកឃើញផ្នែកអង្គហេតុដែលគេបានជម្រះរួចហើយពីសំណុំរឿង 00២/0១ ឡើយ។ ផ្ទុយទៅវិញ ការរកឃើញអង្គហេតុ និងសាលក្រមក្នុងសំណុំរឿង 00២/0២ គួរផ្អែកលើសក្ខីកម្ម ឯកសារ និងភ័ស្តុតាងដទៃទៀត ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងនោះ រួមមានទាំងភ័ស្តុតាងដែលមាននៅក្នុងកំណត់ហេតុដែលបានបង្ហាញនៅក្នុងសំណុំរឿង 00២/0១។

៤. សហព្រះរាជអាជ្ញា ក៏សូមឆ្លៀតយកឱកាសនេះផងដែរ ដើម្បីផ្តល់យោបល់ដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានាថា គឺតាមរយៈសេចក្តីសន្និដ្ឋានដាក់ជូនរបស់សហព្រះរាជអាជ្ញានេះហើយ ដែលរាល់បទចោទប្រកាន់ដែលនៅសេសសល់ទាំងអំបាលម៉ាណ ក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ00២ទាំងមូល នឹងត្រូវបានធ្វើការជំនុំជម្រះក្នុងសំណុំរឿងលេខ00២/0២ ប៉ុន្តែទីតាំងឧក្រិដ្ឋកម្មនានាដែលបានប្រើប្រាស់សម្រាប់គាំទ្រដល់បទចោទប្រកាន់ទាំងនោះ គួរត្រូវបានកម្រិតត្រឹមជាគំរូតំណាងឲ្យឧក្រិដ្ឋកម្មនានាបានហើយ។ សហព្រះរាជអាជ្ញាសូមជូនជាមតិថា វិធីសាស្ត្រនេះគឺស្របគ្នាជាមួយនឹងសេចក្តីសម្រេច “លើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច

---

[1] ឯកសារលេខ **E301** អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការក្នុងសំណុំរឿង 00២/00២, ៨ វិច្ឆិកា ២០១៣។

ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២"[2] របស់អង្គជំនុំជម្រះតុលាការកំពូលទាំងស្រុង និងជាមួយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល "លើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងវិសាលភាពនៃសំណុំរឿងលេខ០០២/០១"[3]។ ដូចបានណែនាំដោយអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញានឹងត្រៀមលក្ខណៈជាស្រេចដើម្បីធ្វើនូវសេចក្តីសន្និដ្ឋានដាក់ជូនថែមទៀត និងកាន់តែលម្អិតជាងនេះលើសំណើនេះ នៅក្នុងអម្លុងពេល ឬមុនពេលនៃកិច្ចប្រជុំរៀបចំសវនាការ។

៥. សហព្រះរាជអាជ្ញាយល់ឃើញថា សវនាការលើសំណុំរឿង០០២/០២គប្បីចាប់ផ្តើមឡើងឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ការឆាប់ចាប់ផ្តើមធ្វើសវនាការគឺ៖ ទីមួយ វានឹងបង្កើនបាននូវឱកាស សម្រាប់បញ្ចប់កិច្ចដំណើរការនីតិវិធី និងកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ស្តីពីបទចោទទាំងឡាយនោះ ទីពីរ វាត្រូវទៅតាមសិទ្ធិរបស់ជនជាប់ចោទស្តីពីការទទួល បាននូវការកាត់ក្តីដ៏ឆាប់រហ័ស និង ទីបី វាបានកម្រិតនូវរាល់ការចំណាយលើកិច្ចប្រតិបត្តិការនានា របស់អង្គជំនុំជម្រះ ដោយការរំកិល អ.វ.ត.ក ឲ្យខិតកាន់តែជិតទៅដល់ការបញ្ចប់នូវអាណត្តិរបស់ខ្លួន។ សហព្រះរាជអាជ្ញា សូមស្នើរបៀបវារៈ រួមមាន កាលបរិច្ឆេទដែលបានដាក់ស្នើដោយភាគីនីមួយៗដែលទាក់ទង ថាតើពួកគេអាចដាក់ជូនបញ្ជីឈ្មោះសាក្សីដែលបានស្នើសុំនៅពេលណា និងកាលបរិច្ឆេទដ៏ឆាប់បំផុតដែលពួកគេនឹងត្រូវត្រៀមខ្លួនឲ្យរួចជាស្រេច សម្រាប់ការចាប់ផ្តើមសវនាការលើភស្តុតាងនានា នៅក្នុងសំណុំរឿង០០២/០២៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |

[2] ឯកសារលេខ **E284/4/7** សេចក្តីសម្រេច លើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៣ កក្កដា ២០១៣។

[3] ឯកសារលេខ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញា អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងអំពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៨ កុម្ភៈ ២០១៣។